ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

# បទបង្ហាញស្តីពី

# បទប្បញ្ញត្តិ និងការរៀបចំដែនដីតំបន់បឹងទន្លេសាប សម្រាប់ការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព

# មាតិកា

I. ស្ថានភាពទូទៅនៃបឹងទន្លេសាប
II. ស្ថានភាពប្រើប្រាស់ដីក្នុងបឹងទន្លេសាប
III. គោលគំនិតនៃការរៀបចំបទប្បញ្ញត្តិប្រើប្រាស់ដីក្នុងតំបន់ជុំវិញបឹងទន្លេសាប
IV. ទស្សនទានការប្រើប្រាស់ដីជុំវិញទន្លេសាបក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង
V. ចំណុចរសើបនៃវដ្តទឹករបស់បឹងទន្លេសាប និងទន្លេសាប

# I. ស្ថានភាពទូទៅនៃបឹងទន្លេសាប

ផែនទីព្រំប្រទល់រដ្ឋបាលខេត្តជុំវិញបឹងទន្លេសាប



# I. ស្ថានភាពទូទៅនៃបឹងទន្លេសាប

- បឹងទន្លេសាប គឺជាបឹងធម្មជាតិធំជាងគេនៅអាស៊ីអាគ្នេយ៍ ហើយមានប្រព័ន្ធអេកូឡូស៊ីច្រើនប្រភេទ ដូចជាតំបន់វាលលំហទឹកសាប (តួបឹង) វាល់ភក់ ព្រៃលិចទឹក វាលស្មៅលិចទឹក និងតំបន់ទំនាបលិចទឹកនៅជុំវិញ។
- បឹងនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សារបបទឹក លំនឹងអាកាសធាតុក្នុងតំបន់ ទប់ស្កាត់និងកាត់បន្ថយគ្រោះទឹកជំនន់ សម្បូរណ៍ទៅដោយជីវចម្រុះ និងធនធានធម្មជាតិសម្បូរណ៍បែបជាពិសេសព្រៃលិចទឹកដែលជាជម្រកត្រីពង ព្រមទាំងផ្តល់នូវតម្លៃសេដ្ឋកិច្ចប្រមាណ ២ ០០០ លានដុល្លារក្នុងមួយឆ្នាំ។

# I. ស្ថានភាពទូទៅនៃបឹងទន្លេសាប

- តំបន់ទន្លេសាបចាប់គិតពីផ្លូវជាតិលេខ៥ និងលេខ៦ចុះទៅបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្រ្ត ខេត្តចំនួន៦ រួមមានខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ធំ និងត្រូវបានបែងចែកជា៣តំបន់ គឺ ÷

**តំបន់១ ÷** ជាតំបន់ភូមិដ្ឋានរបស់ប្រជាពលរដ្ឋអាចផ្តល់សិទ្ធិជាកម្មសិទ្ធិជូនប្រជាពលរដ្ឋបាន។ មានទំហំប្រមាណ ៣៩ម៉ឺន ហិកតា ។

**តំបន់២ ÷** ជាតំបន់ទ្រនាប់ដែលស្ថិតនៅចន្លោះរវាងតំបន់១ និងតំបន់៣ ដែលតំបន់នេះអាចផ្តល់សិទ្ធិប្រើប្រាស់និងអាស្រ័យផលជូនប្រជាពលរដ្ឋដែលបានបង្កបង្កើនផលជាលក្ខណៈគ្រួសារយូរយារមកហើយ។ មានទំហំប្រមាណ ៣៧ម៉ឺន ហិកតា។

**តំបន់៣÷** ជាតំបន់ព្រៃលិចទឹកដែលត្រូវធ្វើការអភិរក្សហាមប៉ះពាល់ដាច់ខាត។ មានទំហំប្រមាណ ៦៤ម៉ឺន ហិកតា ត្រូវបានកំណត់ដោយអនុក្រឹត្យលេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១។

# II. ស្ថានភាពការប្រើប្រាស់ទឹកដីក្នុងតំបន់បឹងទន្លេសាប

## ការតាំងទីលំនៅតាមបណ្តោយទន្លេ















រូបថត៖ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

# II. ស្ថានភាពការប្រើប្រាស់ទឹកដីក្នុងតំបន់បឹងទន្លេសាប

## ស្ថានភាពដីកោះតាមបណ្ដោយទន្លេសាប




រូបថត៖ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

# II. ស្ថានភាពការប្រើប្រាស់ទឹកដីក្នុងតំបន់បឹងទន្លេសាប

## សក្តានុពលទេសចរណ៍ទាំងផ្លូវទឹក និងផ្លូវគោក





រូបថត៖ ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤

## III. គោលគំនិតនៃការរៀបចំបទប្បញ្ញត្តិប្រើប្រាស់ដីក្នុងតំបន់ជុំវិញបឹងទន្លេសាប

- ផែនការរៀបចំដែនដីជាការងារអន្តរវិស័យ
- ការធ្វើសមាហរណកម្មផែនការប្រើប្រាស់ដី ជាមួយនឹងការងារគ្រប់គ្រង និងអភិរក្សធនធានទឹក មានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយសារការងារនេះបានរួមចំណែកដោះស្រាយបញ្ហាដ៏ស្មុគស្មាញរវាងសកម្មភាពមនុស្ស បំរែបំរួលការប្រើប្រាស់ដី និងវដ្តធារាសាស្ត្រ។
- ជំរុញការអភិវឌ្ឍន៍ដែលមានការសម្របសម្រួល និងការគ្រប់គ្រងទឹក ដី និងធនធានពាក់ព័ន្ធ ដើម្បីសុខុមាលភាពសេដ្ឋកិច្ច និងសង្គម ដោយមិនប៉ះពាល់ដល់ចីរភាពនៃប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ។
- ការធ្វើផែនការរៀបចំដែនដី អាចមានឥទ្ធិពលលើគុណភាពទឹក តាមរយៈបទប្បញ្ញត្តិកំណត់តំបន់ប្រើប្រាស់ដី ដែលនឹងគ្រប់គ្រងសកម្មភាពប្រើប្រាស់ដីនៅក្នុងតំបន់ជាក់លាក់ណាមួយ ដូចជាតំបន់ឧស្សាហកម្ម តំបន់កសិកម្ម ឬតំបន់លំនៅដ្ឋាន។

## សេចក្តីព្រាងគោលគំនិតនៃការរៀបចំបទប្បញ្ញត្តិប្រើប្រាស់ដីក្នុងតំបន់ជុំវិញបឹងទន្លេសាប

ក្នុងគោលដៅចូលរួមចំណែកប្រើប្រាស់ធនធានធម្មជាតិតាមបណ្តោយទន្លេសាបក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំងឱ្យចំទិសដៅ មានប្រសិទ្ធភាពខ្ពស់ និងប្រកបដោយចីរភាព តាមរយៈការអភិវឌ្ឍនិងអភិរក្សនូវមុខងារ តួនាទី លក្ខណៈ សម្បត្តិ និងស្ថានភាពពិសេសនៃទីតាំងនីមួយៗ ដើម្បីបង្កើតការងារធ្វើ មុខរបរ និងប្រាក់ចំណូលសម្រាប់គ្រួសារប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយដងទន្លេសាប ទាំងតំបន់១ តំបន់២ និងទីតាំងដែលមានសក្តានុពលពិសេសមួយចំនួននៃតំបន់៣ ការរៀបចំឱ្យមានបទបញ្ញត្តិនៃការប្រើប្រាស់ដី និងធនធានធម្មជាតិតាមតំបន់នីមួយៗ គឺជាវិធានការ ចាំបាច់ក្នុងការការពារនិងអភិរក្ស ដើម្បីធានាបាននូវការការប្រើប្រាស់ដីចំគោលដៅ មានប្រសិទ្ធភាព និងប្រកបដោយចីរភាព ជាពិសេសក្នុងតំបន់៣ដែលជាតំបន់ការពារនៃទន្លេសាប។ ដូចមានបង្ហាញជាគោលគំនិតនៃការៀបចំតំបន់អភិវឌ្ឍន៍ និងអភិរក្សជាគំរូ នៃតំបន់បឹងទន្លេសាបក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំងគួរយកចិត្តទុកដាក់លើទិដ្ឋភាពខាងក្រោម÷

## ១. ទិដ្ឋភាពប្រវត្តិសាស្ត្រ

ជាប្រវត្តិសាស្ត្រ តាមដងទន្លេ ព្រែក បឹង គឺជាទីតាំងដែលប្រជាពលរដ្ឋកម្ពុជាតែងជ្រើសរើសយកជាភូមិសាស្ត្រសម្រាប់ការតាំងទីលំនៅ ដោយទីតាំងទាំងនេះមានសក្តានុពលដ៏សំខាន់នៅក្នុងការគាំទ្រដល់ ជីវភាពរស់នៅប្រចាំថ្ងៃមានជាអាទិ៍ ប្រភពត្រី ប្រភពទឹកប្រើប្រាស់ ប្រភពទឹកសម្រាប់ការប្រកបរបរកសិកម្មជាដើម -ល- និងជាទីកន្លែងដែលមានសីតុណ្ហភាពអំណោយផលដល់ការរស់នៅ មិនក្តៅពេក មិនត្រជាក់ពេក ដោយសារអាកាសធាតុត្រូវបានផ្លាស់ប្តូរដោយផ្ទៃទឹក។ ដូច្នេះការតាំងទីលំនៅតាមបណ្តោយទន្លេសាប ទន្លេ មេគង្គ និងតាមបណ្តោយទន្លេ ស្ទឹង បឹងដទៃទៀតទូទាំងព្រះរាជាណាចក្រកម្ពុជា កើតមានឡើងដោយកត្តាធម្មជាតិ និងមានជាប្រពៃណីទំនៀមទម្លាប់យូរមកហើយ។ ការទទួលបានសិទ្ធរស់នៅជាអចិន្ត្រៃយ៍ ដោយមានការកែលម្អលើសកម្មភាពប្រកបរបរចិញ្ចឹមជីវិតដើម្បីចីរភាពនៃបរិស្ថាន គួរទទួលបានការយកចិត្តទុក ដាក់ពីរាជរដ្ឋាភិបាល។

## ២. និរន្តរភាពបរិស្ថាន

ទន្លេសាបគឺជាទន្លេដែលមានចរន្តទឹកពីរ គឺចរន្តទឹកហូរចេញពីទន្លេមេគង្គចូលទៅបឹងទន្លេសាបនៅ រដូវវស្សាពីខែមិថុនាដល់ខែតុលា និងចរន្តទឹកហូរចេញពីទន្លេសាបទៅសមុទ្រវិញនៅរដូវប្រាំងពីខែវិច្ឆិកាដល់ ខែឧសភា របបទឹកហូរជាប្រចាំនេះផ្តល់នូវជីវៈចម្រុះពិសេសសម្រាប់ទន្លេសាប និងបឹទន្លេសាបជាពិសេសលក្ខខណ្ឌអនុគ្រោះដល់ពួកមច្ឆា។ ទន្លេសាបនៅក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំងគឺមានប្រភេទដីជាដីស្រែចម្ការ និងលំនៅឋានលិចទឹក មានបណ្តាប្រជុំកោះដែលលិចទឹកនារដូវវស្សា និងកោះដែលមិនលិចទឹក មានទីតាំងដីជាប្រភេទដីសម្រាប់ចម្ការ និងសម្រាប់ស្រែប្រាំង មានដៃទន្លេ ព្រែក ស្ទឹងបែកចេញពីតួទន្លេសាប ជាពិសេសលក្ខណៈពិសេសរបស់ទន្លេសាបនៅក្នុងភូមិសាស្ត្រព្រំប្រទល់ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តកំពង់ធំ គឺជាសរសៃបេះដូងរបស់បឹងទន្លេសាប និងទន្លេមេគង្គដែលទាមទារឱ្យមានផែនការអភិវឌ្ឍ និងអភិរក្សច្បាស់លាស់ដើម្បីការពារទាំងការរួមតូច និងការបំពុលនៃសរសៃបេះដូងទន្លេសាបក្នុងភូមិសាស្ត្រព្រំប្រទល់ខេត្តទាំង៣ផងដែរ។ ដូច្នេះការរៀបចំផែនការប្រើប្រាស់ដីក្នុងភូមិសាស្ត្រព្រំប្រទល់នៃខេត្តទាំង៣ គឺជាការចាំបាច់បំផុតក្នុងការអភិវឌ្ឍនិងអភិរក្សទាំងបឹងទន្លេសាប និងទន្លេសាបទាំងមូល (ដូចមានភ្ជាប់ជូនមកជាមួយនូវផែនទីបង្ហាញទីតាំង)។ ទីតាំងខាងលើនេះគឺជាទីតាំងដែលងាយរងនូវហានិភ័យខ្ពស់ដោយសារ១) ជាទីតាំងដែលត្រូវបានគ្រប់គ្រងដោយរដ្ឋបាលខេត្តចំនួន៣ដែលអាចរងនូវការរុញច្រានសមត្ថភាពទៅវិញទៅមក ២) ជាទីតាំងដែលតាមការពិនិត្យមើលតាមរយៈរូបថតពីលើអាកាសគឺនៅរដូវប្រាំងមានការធ្វើស្រែប្រាំងដែលជាមូលហេតុធ្វើច្រោះដីបិទរួមផ្លូវទឹកកាន់តែតូចចំពោះដៃទន្លេសាប ដែលជាកត្តាទាមទារឱ្យមានការរៀបចំផែនការប្រើប្រាស់ដីចំពោះទីតាំងនេះឱ្យមានភាពច្បាស់លាស់ និងការយកទៅអនុវត្តឱ្យមានភាពម៉ឺងម៉ាត់ផងដែរ។

## ៣. និជ្ជភាពសង្គម

ជាប្រវត្តិសាស្ត្រ ប្រជាពលរដ្ឋបានមកតាំងទីលំនៅតាំងពីបុរាណមកហើយ ដោយប្រកបរបរចិញ្ចឹមជីវិតជាទំនៀមទម្លាប់តាមបែបអ្នកដងទន្លេមានដូចជា ការនេសាទ ការដាំដំណាំកសិកម្មមានដូចជាស្រែប្រាំង ចម្ការ ការចិញ្ចឹមត្រីវារីវប្បកម្មជាដើម។ល។ ការតាំងទីលំនៅរបស់ប្រជាពលរដ្ឋ គឺអាស្រ័យទៅលើការឡើងចុះរបស់ទឹកទន្លេ ការតាំងទីលំនៅនៅលើក្បូន នៅលើទូក ឬផ្ទះបណ្តែតទឹក រួមទាំងបណ្តាសេវាកម្ម សង្គមមួយចំនួនក៏មានស្ថានភាពដូចគ្នា គឺនៅជាមួយការតាំងទីលំនៅរបស់ប្រជាពលរដ្ឋនៅលើទឹក។ ដូច្នេះ ការទទួលបាននូវសេវាសង្គមមានដូចជា សេវាសុខភាព សេវាអប់រំ និងសេវាគាំទ្រមួយចំនួនទៀតគឺនៅមានកម្រិតបំផុតដោយសារការតាំងទីលំនៅរបស់ប្រជាពលរដ្ឋនៅលើទឹក ហើយផ្លាស់ប្តូរទីតាំងទៅតាមកម្ពស់ទឹក ហើយការតាំងទីលំនៅមិនមានលក្ខណៈប្រមូលផ្តុំ មានការរស់នៅជាបណ្តុំតូចៗ ដែលពិបាកនៅក្នុងការរៀបចំផ្តល់សេវាសង្គម និងសេវាសាធារណៈផ្សេងៗទៀត។ ជាប្រពៃណីទំនៀមទម្លាប់ការរស់នៅដោយតាំងទីលំនៅបណ្តែតទឹកមានមូលដ្ឋានសេដ្ឋកិច្ចធំលើការនេសាទ និងការដាំស្រែប្រាំង ឬចម្ការនៅរដូវទឹកស្រក។

ក្នុងទិដ្ឋភាពខាងលើ និងជាប្រពៃណីទំនៀមទំលាប់ផង ការតាំងទីលំនៅជាភូមិឋានតាមបណ្តោយទន្លេ ស្ទឹង បឹង និងអូរនៅតាមតំបន់ទន្លេសាប គួរទទួលបានការអនុញ្ញាត និងរៀបចំជាផែនការប្រើប្រាស់ដីជាភូមិឋានក្បែមក្សាន្ត ជូនគ្រួសារប្រជាពលរដ្ឋ។

## ៤. ទិដ្ឋភាពសេដ្ឋកិច្ច

- **វិស័យទេសចរណ៍÷** រាជរដ្ឋាភិបាលគួររៀបចំផែនការប្រើប្រាស់ដី ជាពិសេសសម្រាប់បណ្តាប្រជុំកោះនៅតាមបណ្ ដោយទន្លេសាបសម្រាប់បម្រើដល់វិស័យទេសចរណ៍ផង និងក្នុងគោលដៅអភិរក្សផង។ កិច្ចការជាចម្បងសម្រាប់រៀបចំបណ្តាកោះឱ្យក្លាយ ជាតំបន់ទេសចរណ៍គឺការអនុញ្ញាតឱ្យបណ្តាសមាគម ឬសហគម និងប្រជាពលរដ្ឋនៅមូលដ្ឋានសហការជាមួយអាជ្ញាធរដែនដីមូលដ្ឋាន និងមន្ទីរទេសចរណ៍រៀបចំកែលម្អផ្ទៃកោះក្នុងស្ថានភាពរក្សាសភាពដើមឱ្យបានកាន់តែច្រើនដែលអាចធ្វើបាន ដើម្បីប្រែក្លាយបណ្តាកោះទាំងនោះទៅជាប្រភេទកោះទេសចរណ៍ធម្មជាតិ។
- **វិស័យវារីវប្បកម្ម÷** រាជរដ្ឋាភិបាលគួររៀបចំជាមូលនិធិ ឬជាកម្ចីដែលមានការប្រាក់អនុគ្រោះ និងការសងរំលស់ទៅតាមការសិក្សានៃលទ្ធភាពសងវិញសមស្របរបស់គ្រួសារប្រជាពលរដ្ឋមូលដ្ឋានក្នុងការយកទៅប្រើប្រាស់សម្រាប់ការរៀបចំជាមុខរបរក្នុងវិស័យទេសចរណ៍ក្នុងសហគម មុខរបរផ្នែកកសិកម្ម ឬមុខរបរផ្នែកវារីវប្បកម្ម ដែលជាការការពារមិនឱ្យប្រជាកសិករនៅមូលដ្ឋានអាចធ្លាក់ក្នុងវិបត្តិបំណុលរបស់ធនាគារឯកជនដែលមានការប្រាក់ខ្ពស់ មិនអាចទូទាត់ក្នុងករណីមានហានិភ័យផ្សេងៗដែលអាចកើតមាននៅក្នុងមុខរបររបស់ខ្លួននិងឈានទៅដល់ការជាប់បំណុលមិនអាចដោះស្រាយបាន ដើម្បីផ្តល់ ជូនដល់គ្រួសារប្រជាពលរដ្ឋនៅមូលដ្ឋានមានលទ្ធភាពស្មើៗគ្នាក្នុងការប្រកបរបរវារីវប្បកម្ម។
- **វិស័យកសិកម្ម÷** លើកទឹកចិត្តឱ្យប្រជាពលរដ្ឋប្រកបរបរកសិកម្ម និងដំណាំនៅរដូវទឹកស្រក់នៅលើទីតាំងដីដែលអាចដាំដុះបានដោយចាំបាច់មិនត្រូវធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងប្រភពទឹកនៅផ្នែកខាងក្រោម ដែលជាប្រភេទកសិកម្មមិនប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតមិនមានស្តង់ដាបទដ្ឋាន និងការណែនាំឱ្យប្រើប្រាស់ឱ្យបានត្រឹមត្រូវ។ ការប្រកបរបរវិស័យកសិកម្ម និងដំណាំចម្ការនៅរដូវទឹកស្រក់ នេះត្រូវចងក្រងជាសហគមន៍ដើម្បីងាយស្រួលក្នុងការណែនាំអំពីផលប៉ះពាល់ដល់បរិស្ថានក៏ដូចជា ការបង្កើតនូវកម្លាំងផលិតមួយដើម្បីចរចាជាមួយនឹងទីផ្សារ និងដើម្បីអាចឈានទៅប្រកបរបរកសិកម្មបែបកិច្ចសន្យា។
- **ការរៀបចំផែតាមបណ្តោយទន្លេសាប** តាមស្ថានភាពភូមិសាស្ត្រ និងសក្តានុពលសេដ្ឋកិច្ចរបស់ទីតាំងដែលត្រូវរៀបចំផែ អាចអនុញ្ញាតិឱ្យទីតាំងដីនៅជាប់ផែ អាចរៀបចំជាតំបន់សេដ្ឋកិច្ច ដែលលើកទឹកចិត្តឱ្យមានការវិនិយោគផ្នែកភស្តុភារកម្ម រោងចក្រ សហគ្រាសដែលប្រើប្រាស់ធនធាននៅក្នុងភូមិសាស្ត្រមូលដ្ឋាន និងការវិនិយោគសេវាគាំទ្រដទៃទៀត។

## ៥. និរន្តរភាពអភិរក្ស

ទោះបីជាធនធានធម្មជាតិដែលមានតាមបណ្តោយទន្លេសាប និងតំបន់ជុំវិញអាចត្រូវបានយកមកអភិវឌ្ឍសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ការបង្កើតមុខរបរ ការបង្កើនប្រាក់ចំណូលកែលម្អជីវភាពរស់នៅរបស់គ្រួសាររបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក៏ការអភិវឌ្ឍទាំងនេះត្រូវដើរទន្ទឹមគ្នានិងការអភិរក្សនូវធនធានធម្មជាតិទាំងអស់នេះ។ ក្នុងករណីមានតែការអភិវឌ្ឍដោយមិនមានការអភិរក្ស ការអភិវឌ្ឍអាចនឹងត្រូវបញ្ចប់ក្នុងរយៈពេលខ្លីដោយមូលហេតុការបាត់បង់ ការប៉ះពាល់ការបំពុលទៅលើធនធានធម្មជាតិដោយចៀសមិនផុត។ ដូច្នេះការរៀបចំកសាងផែនការប្រើប្រាស់ដីតាមបណ្តោយដងទន្លេសាប ឬតាមទីតាំងសំខាន់ៗ នៃទន្លេសាបនិងបណ្តាប្រជុំកោះនានាគឺជាការចាំបាច់ដើម្បីកំណត់អំពីកិច្ចការអភិវឌ្ឍដោយមានការអភិរក្ស។

ក្នុងគោលដៅទទួលបាននូវការអភិវឌ្ឍន៍ និងអភិរក្សតំបន់ទន្លេសាបប្រកបដោយចីរភាពរាល់បណ្តាប្រភពទឹកសំខាន់ៗមានដូចជាទន្លេ បឹង ស្ទឹង ព្រែក អូរ ប្រឡាយ គួរត្រូវបានការថែរក្សាស្ថានភាពដើម ឬត្រូវមានកម្មវិធីស្តាររក្សាបាននូវជម្រៅទឹកសម្រាប់ប្រើប្រាស់ក្នុងគោលដៅចាំបាច់នានាតាមស្ថានភាពជាក់ស្តែង។

## ៦. និរន្តរភាពនយោបាយ

ការជួយជ្រោមជ្រែងនិងអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធប្រើប្រាស់ដី ក្នុងរូបភាពជាសិទ្ធប្រើប្រាស់អាស្រ័យផលអចិន្ត្រៃយ៍ទៅលើធនធានធម្មជាតិតាមបណ្តោយទន្លេសាប និងតំបន់អភិរក្សមួយចំនួន និងទទួល បាននូវការគាំទ្រត្រឡប់មកវិញពីប្រជាពលរដ្ឋដែលកាន់កាប់និងអាស្រ័យផល ក្នុងពេលតែមួយការជឿជាក់ទៅលើគោលនយោបាយរបស់រាជរដ្ឋាភិបាលទៅលើការងារអភិរក្ស និងអភិវឌ្ឍក៏កាន់តែច្បាស់លាស់ និងមានកំណើននៃការចូលរួមពីសហគមមូលដ្ឋាន និងប្រជាពលរដ្ឋជាមួយរាជរដ្ឋាភិបាលចំពោះការងារអភិរក្ស និងអភិវឌ្ឍដើម្បីគោលដៅអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងបរិស្ថានប្រកបដោយចីរភាព។

# IV. ទស្សនទានការប្រើប្រាស់ដីជុំវិញទន្លេសាបក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង

## កំណត់សម្គាល់

- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ស្រុក

### ប្រភេទតំបន់ប្រើប្រាស់ដី

- តំបន់លំនៅឋាន
- តំបន់សេដ្ឋកិច្ច
- តំបន់ឧស្សាហកម្មឡឥដ្ឋ
- តំបន់កសិទេសចរណ៍
- តំបន់ទេសចរណ៍ធម្មជាតិ
- តំបន់កសិកម្ម
- តំបន់វារីវប្បកម្ម
- តំបន់ការពារ
- ផ្ទៃទឹក



# V. ចំណុចរសើបនៃវដ្តទឹករបស់បឹងទន្លេសាប និងទន្លេសាប






©Ministry of Environment of Cambodia